រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ៤៧៧៣ ប្រ.ក

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ប្រកាស
## ស្តីពី
## ការប្រគល់សិទ្ធិការងារតែងតាំងមុខតំណែង តម្លើងឋានន្តរស័ក្តិ ផ្ទេរភារកិច្ចមន្ត្រីនគរបាលជាតិ និងរៀបចំរចនាសម្ព័ន្ធ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ ន.ស ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីការលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញប្រកាសលេខ ៤៤៩ ប្រក ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ១៩៩៧ របស់ក្រសួងមហាផ្ទៃ ស្តីពីការរៀបចំឋានន្តរស័ក្តិកងកម្លាំងនគរបាលជាតិ
- បានឃើញប្រកាសលេខ ៤៤៤ ប្រ.ក ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ១៩៩៩ របស់ក្រសួងមហាផ្ទៃ ស្តីពីការប្រគល់សិទ្ធកំណត់រៀបចំរចនាសម្ព័ន្ធ តែងតាំងមុខតំណែងឋានន្តរសក្តិ និងផ្ទេរភារកិច្ចមន្ត្រីនគរបាលជាតិ
- តាមតម្រូវការចាំបាច់របស់ក្រសួងមហាផ្ទៃ

## សម្រេច

**ប្រការ ១ :** ត្រូវបានប្រគល់សិទ្ធិជូនអគ្គស្នងការនគរបាលជាតិ អគ្គនាយក និងថ្នាក់ប្រហាក់ប្រហែល លើការងារតែងតាំងមុខតំណែង តម្លើងឋានន្តរសក្តិ ផ្ទេរភារកិច្ចមន្ត្រីនគរបាលជាតិ និងរៀបចំរចនាសម្ព័ន្ធ ដូចខាងក្រោម ៖

*ក-អគ្គស្នងការនគរបាលជាតិ:*

ចេញសេចក្តីសម្រេចតែងតាំងមុខតំណែង តម្លើងឋានន្តរសក្តិ ផ្ទេរភារកិច្ចមន្ត្រីនគរបាលជាតិ និងរៀបចំរចនាសម្ព័ន្ធ ដូចខាងក្រោម ៖

ក១-មុខតំណែង:

-នាយ នាយរងផ្នែក ចំណុះការិយាល័យ នៃនាយកដ្ឋាន-អង្គភាពក្រោមឱវាទ

-នាយ នាយរងផ្នែក ចំណុះការិយាល័យ នៃស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត

-នាយ នាយរងផ្នែក នាយ នាយរងប៉ុស្តិ៍នគរបាលរដ្ឋបាលចំណុះអធិការដ្ឋានក្រុង-ស្រុក-ខណ្ឌ

-នាយ នាយរងផ្នែក នាយ នាយរងប៉ុស្តិ៍ចំណុះវរសេនាតូចការពារព្រំដែនគោក ព្រំដែនទឹក

ក២-ឋានន្តរសក្តិ: ចាប់ពីអនុសេនីយ៍ឯកចុះ ។

ក៣-ផ្ទេរភារកិច្ចមន្ត្រីនគរបាលជាតិពីអង្គភាពមួយទៅអង្គភាពមួយចំណុះអគ្គស្នងការដ្ឋាននគរបាលជាតិ និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ចាប់ពីថ្នាក់នាយផ្នែក និងឋានន្តរស័ក្តិចាប់ពីអនុសេនីយ៍ឯកចុះ ។

ក៤-របនាសម្ព័ន្ធ: រៀបចំរបនាសម្ព័ន្ធចាប់ពីថ្នាក់ផ្នែកចំណុះការិយាល័យនៃនាយកដ្ឋាន-អង្គភាព ថ្នាក់ផ្នែកចំណុះការិយាល័យ ថ្នាក់ផ្នែកចំណុះ អធិការដ្ឋាននគរបាលក្រុង-ស្រុក-ខណ្ឌនៃស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត និងថ្នាក់ផ្នែក ថ្នាក់ប៉ុស្តិ៍ ចំណុះវរសេនាតូចនគរបាលការពារព្រំដែនគោក ព្រំដែនទឹក ។

ខ-អគ្គនាយកអន្តោប្រវេសន៍:

ចេញសេចក្តីសម្រេចតែងតាំងមុខតំណែង តម្លើងឋានន្តរសក្តិ និងផ្ទេរភារកិច្ចមន្ត្រីនគរបាលជាតិ ដូចខាងក្រោម ៖

ខ១-មុខតំណែង:

-នាយ នាយរងផ្នែក ចំណុះការិយាល័យ នៃនាយកដ្ឋានក្រោមឱវាទ

-នាយ នាយរងផ្នែក ចំណុះប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិ ប៉ុស្តិ៍ច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិ និងប៉ុស្តិ៍ច្រកទ្វារកំពង់ផែអន្តរជាតិ

ខ២-ឋានន្តរសក្តិ: ចាប់ពីអនុសេនីយ៍ឯកចុះ

ខ៣-ផ្ទេរភារកិច្ចមន្ត្រីនគរបាលជាតិនៃនាយកដ្ឋាន អង្គភាព ក្រោមឱវាទ ចាប់ពីថ្នាក់នាយផ្នែក និងឋានន្តរស័ក្តិចាប់ពីអនុសេនីយ៍ឯកចុះ ។

ខ៤-របនាសម្ព័ន្ធ: រៀបចំរបនាសម្ព័ន្ធចាប់ពីថ្នាក់ផ្នែកចំណុះការិយាល័យនៃនាយកដ្ឋាន និងថ្នាក់ផ្នែកចំណុះប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិ ប៉ុស្តិ៍ច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិ និងប៉ុស្តិ៍ច្រកទ្វារកំពង់ផែអន្តរជាតិ ។

គ-អគ្គលេខាធិការ អគ្គនាយកភស្តុភារនិងហិរញ្ញវត្ថុ អគ្គនាយកអត្តសញ្ញាណកម្ម និងប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា និងថ្នាក់ប្រហាក់ប្រហែល:

ចេញសេចក្តីសម្រេចតែងតាំងមុខតំណែង តម្លើងឋានន្តរសក្តិ និងផ្ទេរភារកិច្ចមន្ត្រីនគរបាលជាតិ រៀបចំរបនាសម្ព័ន្ធ ដូចខាងក្រោម ៖

គ១-មុខតំណែង:

-នាយ នាយរងផ្នែក ចំណុះការិយាល័យ នៃនាយកដ្ឋាន-អង្គភាពក្រោមឱវាទ

គ២-ឋានន្តរសក្តិ: ចាប់ពីអនុសេនីយ៍ឯកចុះ

គ៣-ផ្ទេរភារកិច្ចមន្ត្រីនគរបាលជាតិពីអង្គភាពមួយទៅអង្គភាពមួយ ក្រោមឱវាទចាប់ពីថ្នាក់នាយផ្នែក និងឋានន្តរស័ក្តិចាប់ពីអនុសេនីយ៍ឯកចុះ ។

គ៤-របនាសម្ព័ន្ធ: រៀបចំរបនាសម្ព័ន្ធចាប់ពីថ្នាក់ផ្នែកចំណុះការិយាល័យនៃនាយកដ្ឋាន-អង្គភាព ក្រោមឱវាទ ។

**ប្រការ ២ ៈ** ការតែងតាំងមុខតំណែង និងតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិ ស្ថិតក្រោមសមត្ថកិច្ចរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ៖

ក-មុខតំណែង:

**ក១-នៅក្រសួង**

-អនុប្រធាននាយកដ្ឋាន

-នាយ នាយរងការិយាល័យ ចំណុះនាយកដ្ឋាន-អង្គភាព

-នាយ នាយរងប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិ ប៉ុស្តិ៍ច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិ និងប៉ុស្តិ៍ច្រកទ្វារកំពង់ផែអន្តរជាតិ

-មេបញ្ជាការ មេបញ្ជាការរងវរសេនាតូចការពារព្រំដែនគោក-ទឹក

**ក២-ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត**

-ស្នងការ ស្នងការរងនគរបាលរាជធានី-ខេត្ត

-នាយ នាយរងការិយាល័យ អធិការ អធិការរងនគរបាលក្រុង-ស្រុក-ខណ្ឌ ចំណុះស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត

-មេបញ្ជាការ មេបញ្ជាការរងវរសេនាតូចនគរបាលការពារព្រំដែនគោក

ខ-ឋានន្តរសក្តិ: ថ្នាក់វរសេនីយ៍ត្រី និងថ្នាក់វរសេនីយ៍ទោ ។

គ-ផ្ទេរភារកិច្ចមន្ត្រីនគរបាលជាតិ ពីអគ្គនាយកដ្ឋានមួយ ទៅអគ្គនាយកដ្ឋានមួយទៀត ចំណុះក្រសួងមហាផ្ទៃ ។

**ប្រការ ៣ ៈ** អំពីរបៀបរបបការងារតែងតាំងមុខតំណែង តម្លើងឋានន្តរស័ក្តិ ផ្ទេរភារកិច្ចមន្ត្រីនគរបាលជាតិ និងការរៀបចំរចនាសម្ព័ន្ធ:

១- សមត្ថកិច្ចរបស់អគ្គស្នងការនគរបាលជាតិ:

គ្រប់នាយកដ្ឋាន-អង្គភាព និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ត្រូវលើកសំណើតាមរយ:នាយកដ្ឋានបុគ្គលិក ដើម្បីពិនិត្យលើកយោបល់ និងរៀបចំបែបបទតាមនីតិវិធីជូនអគ្គស្នងការនគរបាលជាតិ ពិនិត្យសម្រេច ។

២-សមត្ថកិច្ចរបស់អគ្គនាយក និងថ្នាក់ប្រហាក់ប្រហែល:

គ្រប់នាយកដ្ឋាន-អង្គភាព ត្រូវលើកសំណើតាមរយ:នាយកដ្ឋានបុគ្គលិក ដើម្បីពិនិត្យលើកយោបល់ និងរៀបចំបែបបទតាមនីតិវិធីជូនអគ្គនាយកនៃអគ្គនាយកដ្ឋានសាមី ពិនិត្យសម្រេច ។

៣-សមត្ថកិច្ចរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ:

អគ្គលេខាធិការដ្ឋាន អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានកសុភារនិងហិរញ្ញវត្ថុ បណ្ឌិត្យសភានគរបាលកម្ពុជា អគ្គាធិការដ្ឋាន អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងថ្នាក់ប្រហាក់ប្រហែល ត្រូវលើកសំណើជូនរដ្ឋមន្ត្រី ដោយមាននាយកដ្ឋានបុគ្គលិកធ្វើជាសេនាធិការ ដើម្បីពិនិត្យលើកយោបល់សុំការឯកភាពពីអគ្គលេខាធិការទទួលផែន និងរៀបចំបែបបទតាមនីតិវិធីដាក់ជូនរដ្ឋមន្ត្រីពិនិត្យសម្រេច ។

**ប្រការ ៤ ៈ** អំពីនីតិវិធីនៃការតែងតាំងមុខតំណែង តម្លើងឋានន្តរសក្តិ ផ្ទេរភារកិច្ចមន្ត្រីនគរបាលជាតិ និងការរៀបចំរចនាសម្ព័ន្ធ និងមានការកំណត់ដោយឡែក ។

**ប្រការ ៥ ៖** នាយកដ្ឋានបុគ្គលិកមានភារកិច្ចធ្វើជាសេនាធិការជូនរដ្ឋមន្ត្រី អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋាន និងថ្នាក់ប្រហាក់ប្រហែល លើរាល់ការងារបុគ្គលិកផ្នែកនគរបាលជាតិ ។

**ប្រការ ៦ ៖** រាល់ការកំណត់ទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៧ ៖** អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា អគ្គាធិការនៃអគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និងនគរបាល អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ប្រធានក្រុមប្រឹក្សាវិនិច្ឆ័យ ប្រធានក្រុមប្រឹក្សានីតិកម្ម ប្រធាននាយកដ្ឋានកណ្តាលមធ្យោបាយ ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋាន-អង្គភាពពាក់ព័ន្ធ និងស្នងការនៃស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ.ថ្ងៃទី២១ ខែឧសភា ឆ្នាំ ២០១៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមហាផ្ទៃ**
**អគ្គស្នងការដ្ឋាននគរបាលជាតិ**
**នាយកដ្ឋានកណ្តាលមនោគមវិជ្ជា**
**នាយកដ្ឋានបុគ្គលិក**

លេខ: ៧២៣០ លស.បល

រាជធានីភ្នំពេញ,ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១៥

## គោរពជូន
## ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**កម្មវត្ថុ :** សំណើគោលការណ៍ស្តីពីការប្រគល់សិទ្ធិការងារតែងតាំងមុខតំណែង តម្លើងឋានន្តរសក្តិ ផ្ទេរភារកិច្ចមន្ត្រីនគរបាលជាតិ និងរៀបចំរចនាសម្ព័ន្ធ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ *នាយកដ្ឋានបុគ្គលិក* មានកិត្តិយសសូមគោរពជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មេត្តាជ្រាបថា: កន្លងមកក្រសួងមហាផ្ទៃបានប្រគល់សិទ្ធិក្នុងការកំណត់រៀបចំរចនាសម្ព័ន្ធ តែងតាំងមុខតំណែង តម្លើងឋានន្តរសក្តិ និងផ្ទេរភារកិច្ចមន្ត្រីនគរបាលជាតិ ជូនអគ្គស្នងការនគរបាលជាតិ (ប្រកាសលេខ ៤៤៤ ប្រ.ក ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ១៩៩៩ )។

ដោយបច្ចុប្បន្នក្រសួងមហាផ្ទៃមានអគ្គនាយកដ្ឋានច្រើន ហេតុនេះ ដើម្បីឱ្យការងារបុគ្គលិកដំណើរការទៅដោយលូនស្របតាមគោលការណ៍ និងនីតិវិធី នាយកដ្ឋានបុគ្គលិក បានរៀបចំពង្រាងប្រកាសស្តីពីការប្រគល់សិទ្ធិការងារតែងតាំងមុខតំណែង តម្លើងឋានន្តរសក្តិ ផ្ទេរភារកិច្ចមន្ត្រីនគរបាលជាតិ និងរៀបចំរចនាសម្ព័ន្ធ ក្នុងនោះ ៖

**ក-**សមត្ថកិច្ចរដ្ឋមន្ត្រីក្រសួងមហាផ្ទៃមាន ៖

ក១-តែងតាំងមុខតំណែង:

-អនុប្រធាននាយកដ្ឋាន,នាយ-នាយរងការិយាល័យ ចំណុះនាយកដ្ឋាន-អង្គភាព,នាយ-នាយរងប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិ ,មេបញ្ជាការ-មេបញ្ជាការរងវរសេនាតូចការពារព្រំដែនគោក-ទឹក

-ស្នងការ-ស្នងការរងនគរបាលរាជធានី-ខេត្ត,នាយ-នាយរងការិយាល័យ, អធិការ-អធិការរងនគរបាលក្រុង-ស្រុក-ខណ្ឌ ចំណុះស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ។

ក២-តម្លើងឋានន្តរសក្តិ:

-ថ្នាក់វរសេនីយ៍ត្រី និងថ្នាក់វរសេនីយ៍ទោ

**ខ-**ប្រគល់សិទ្ធិជូនអគ្គស្នងការនគរបាលជាតិ អគ្គនាយក និងថ្នាក់ប្រហាក់ប្រហែល ៖

ខ១-តែងតាំងមុខតំណែង:

-នាយ-នាយរងផ្នែក ចំណុះការិយាល័យនាយកដ្ឋាន-អង្គភាព,នាយ-នាយរងផ្នែក ,នាយ-នាយរងប៉ុស្តិ៍ចំណុះស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ។

ខ២-តម្លើងឋានន្តរសក្តិ:

-ថ្នាក់អនុសេនីយ៍ឯកចុះ ។

អាស្រ័យដូចបានជំរាបជូនខាងលើ សូមឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មេត្តាពិនិត្យ និងមានយោបល់សម្រេចដ៏ខ្ពង់ខ្ពស់ ។

សូមឯកឧត្តម មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីយើងខ្ញុំ .

**អគ្គស្នងការរង និងជាប្រធាននាយកដ្ឋានបុគ្គលិក**

នាយឧត្តមសេនីយ៍.ខាន់_ភីរ៉ង